**សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត**

**នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា**

# សារលិខិត

## សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ក្នុងឱកាសទិវាពិភពលោកប្រយុទ្ធនឹងជំងឺអេដស៍ ១ ធ្នូ ឆ្នាំ២០២៥ ក្រោមប្រធានបទ «យកឈ្នះការរំខាន បរិវត្តកម្មឆ្លើយតបនឹងជំងឺអេដស៍» ថ្ងៃចន្ទ ១១កើត ខែមិគសិរ ឆ្នាំម្សាញ់ សប្តស័ក ព.ស.២៥៦៩ ត្រូវនឹងថ្ងៃទី១ ខែធ្នូ ឆ្នាំ២០២៥

- សូមក្រាបថ្វាយបង្គំសម្តេចព្រះមហាសង្ឃរាជទាំងពីរគណៈ សម្តេចព្រះសង្ឃនាយក ព្រះសង្ឃនាយករង ព្រះថេរានុត្ថេរៈគ្រប់ព្រះអង្គ ជាទីគោរពសក្ការៈ!
- សម្តេច ទ្រង់ ឯកឧត្តម លោកជំទាវ លោកអ្នកឧកញ៉ា អ្នកឧកញ៉ា ឧកញ៉ា លោក លោកស្រី!
- បងប្អូនជនរួមជាតិជាទីស្រឡាញ់រាប់អាន!

តាងនាមរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា ទូលព្រះបង្គំ ខ្ញុំព្រះករុណា ខ្ញុំសូមចូលរួមជាមួយពិភពលោកទាំងមូល ក្នុងការប្រារព្ធទិវាពិភពលោកប្រយុទ្ធនឹងជំងឺអេដស៍ ១ធ្នូ ឆ្នាំ២០២៥ ក្រោមប្រធានបទ «**យកឈ្នះការរំខាន បរិវត្តកម្មឆ្លើយតបនឹងជំងឺអេដស៍**»។

ការប្រារព្ធទិវាពិភពលោកប្រយុទ្ធនឹងជំងឺអេដស៍ ដែលនឹងប្រព្រឹត្តទៅនៅថ្ងៃទី១ ខែធ្នូ ឆ្នាំ២០២៥ គឺជាកាលានុវត្តភាពថ្មីដ៏សំខាន់មួយ ដើម្បីបង្ហាញពីផលប៉ះពាល់លើការឆ្លើយតបនឹងមេរោគអេដស៍ និងជំងឺអេដស៍ ជាមួយការប្រឈមថ្មីនានា រួមទាំងការកាត់បន្ថយថវិកាពីអ្នកផ្តល់ជំនួយអន្តរជាតិ ក៏ដូចជាដើម្បីបង្ហាញពីចីរភាពនិងភាពធន់របស់ប្រទេស និងសហគមន៍ដែលក្រោកឈរយ៉ាងរឹងមាំក្នុងការការពារសមិទ្ធផលសម្រេចបាន ព្រមទាំងជំរុញការឆ្លើយតបនឹងមេរោគអេដស៍ ឈានឆ្ពោះទៅសម្រេចគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាពនៅឆ្នាំ២០៣០។

ប្រធានបទ «**យកឈ្នះការរំខាន បរិវត្តកម្មឆ្លើយតបនឹងជំងឺអេដស៍**» មានន័យសំខាន់ក្នុងការជំរុញឱ្យសង្គមខិតខំប្រឹងប្រែងបន្តការឆ្លើយតបនឹងមេរោគអេដស៍ និងជំងឺអេដស៍ឱ្យកាន់តែមានប្រសិទ្ធភាព និងមានភាពរឹងមាំជាងមុន។ ការរំខានដូចជា ការរើសអើង ការមាក់ងាយចំពោះអ្នកផ្ទុកមេរោគអេដស៍ ប្រជាជនគន្លឹះ កង្វះការយល់ដឹងត្រឹមត្រូវពីប្រជាពលរដ្ឋ កង្វះធនធានឬកង្វះការយកចិត្តទុកដាក់របស់អ្នកពាក់ព័ន្ធ ដែលតម្រូវឱ្យយើងទាំងអស់ពង្រឹងកិច្ចសហការគ្រប់តួអង្គ ដើម្បីគាស់រំលើងឧបសគ្គទាំងនោះ ហើយជំរុញឱ្យមានបរិវត្តកម្មឬការផ្លាស់ប្តូរដ៏វិជ្ជមានមួយក្នុងការដឹកនាំ គ្រប់គ្រង និងបង្ការជំងឺអេដស៍។ ការយកឈ្នះការរំខាន គឺជាគន្លងដ៏សំខាន់ក្នុងការអភិវឌ្ឍវិធានការឆ្លើយតបនឹងមេរោគអេដស៍និងជំងឺអេដស៍ ប្រកបដោយប្រសិទ្ធភាពនិងសក្តិសិទ្ធិភាព សមស្របតាមការប្រែប្រួលរបស់សង្គម សេដ្ឋកិច្ច និងបច្ចេកវិទ្យា។

មេរោគអេដស៍មិនទាន់បំបាត់អស់នៅឡើយទេ។ ជំងឺអេដស៍នៅតែជាបញ្ហាសុខភាពសាធារណៈមួយដែលបានប៉ះពាល់ដល់ជីវិតមនុស្សជាច្រើន រួមទាំងជះផលអវិជ្ជមានដល់សង្គម សេដ្ឋកិច្ច នៅទូទាំងពិភពលោក។ ទោះជាយ៉ាងណាក៏ដោយ ការឆ្លើយតបរបស់ប្រទេសកម្ពុជា បានធ្វើដំណើរឆ្ពោះទៅមុខគួរឱ្យកត់សម្គាល់ រីឯវិធីសាស្ត្របរិវត្តកម្ម គឺជា

ការចាំបាច់ក្នុងការកាត់បន្ថយហានិភ័យ និងជួយឱ្យសម្រេចបាននូវគោលដៅរួមរបស់យើង ទាំងលើការបង្ការ ការថែទាំ ការព្យាបាល និងការគាំទ្រ។ ប្រទេសកម្ពុជាបានធ្វើការផ្លាស់ប្តូរយ៉ាងខ្លាំង ចំពោះកម្មវិធីប្រយុទ្ធនឹងជំងឺអេដស៍តាមរយៈការដាក់ចេញនូវគោលនយោបាយជាតិបញ្ចប់អេដស៍ និងចីរភាពកម្មវិធីអេដស៍ សម្រាប់ឆ្នាំ២០២៣-២០២៨ របស់រាជរដ្ឋាភិបាល ដោយផ្តោតលើការអនុវត្តអភិក្រម **«ជវភាពនៃប្រព័ន្ធតួអង្គតែមួយ»**។

ជាការពិតណាស់ ការឆ្លើយតបនឹងមេរោគអេដស៍ជាសកលមិនអាចពឹងផ្អែកលើធនធានក្នុងស្រុកតែមួយបានទេ។ សហគមន៍អន្តរជាតិត្រូវតែរួមគ្នា ដើម្បីកាត់បន្ថយគម្លាតថវិកា និងគាំទ្របណ្តាប្រទេសនានា ដើម្បីបិទគម្លាតដែលនៅសេសសល់នៅក្នុងការគាំទ្រសេវាបង្ការ និងព្យាបាលមេរោគអេដស៍ លុបបំបាត់ឧបសគ្គផ្នែកច្បាប់និងសង្គម និងផ្តល់អំណាចដល់សហគមន៍ ក្នុងការចូលរួមដឹកនាំឆ្លើយតប។ ភាពជាអ្នកដឹកនាំនយោបាយ ពិតជាមានសារៈសំខាន់ក្នុងការជំរុញគោលនយោបាយដោយផ្តោតលើការដោះស្រាយវិសមភាព រចនាសម្ព័ន្ធឆ្លើយតប និងការពារប្រជាជនងាយរងគ្រោះដែលបណ្តាលមកពីមេរោគអេដស៍និងជំងឺអេដស៍។

ឆ្លៀតក្នុងឱកាសនេះ ទូលព្រះបង្គំ ខ្ញុំព្រះករុណា ខ្ញុំសូមសម្តែងអំណរសាទរចំពោះសមិទ្ធផល ដែលព្រះរាជាណាចក្រកម្ពុជាយើងសម្រេចបាន ក្នុងការទប់ស្កាត់ការរីករាលដាលនៃមេរោគអេដស៍និងជំងឺអេដស៍ ដូចមានចំណុចសំខាន់ៗ ដូចខាងក្រោមនេះ៖

១- នៅឆ្នាំ២០២៤ អ្នកផ្ទុកមេរោគអេដស៍មានចំនួនប្រមាណ ៧៦ ០០០នាក់ ដែលក្នុងនេះអ្នកផ្ទុកមេរោគអេដស៍ចំនួន ៧១ ៧១៦នាក់ បានទទួលការធ្វើតេស្តរកមេរោគ និងបានដឹងពីស្ថានភាពផ្ទុកមេរោគអេដស៍របស់ពួកគេ និងបានទទួលសេវាថែទាំនិងព្យាបាលដោយឱសថប្រឆាំងមេរោគអេដស៍នៅមូលដ្ឋានសុខាភិបាលរបស់រដ្ឋនៅទូទាំងប្រទេស ស្មើនឹង១០០% ដែលជាអត្រាគ្របដណ្តប់ខ្ពស់ជាងគេនៅតំបន់អាស៊ី-ប៉ាស៊ីហ្វិក។

២- ករណីឆ្លងថ្មីនៃមេរោគអេដស៍បានធ្លាក់ចុះជាបន្តបន្ទាប់ ជាក់ស្តែងការឆ្លងថ្មីនៃមេរោគអេដស៍បានធ្លាក់ចុះពី ១ ៥០០ករណីក្នុងឆ្នាំ២០២៣ មកនៅត្រឹម ១ ២០០ករណីក្នុងឆ្នាំ២០២៤។ ចំណែកឯចំនួនអ្នកស្លាប់ដោយសារមេរោគអេដស៍ក៏បានធ្លាក់ចុះពី ១ ១០០ករណីក្នុងឆ្នាំ២០២៣ មកនៅត្រឹម ១ ០០០ករណីក្នុងឆ្នាំ២០២៤។

៣- អ្នកផ្ទុកមេរោគអេដស៍នៅកម្ពុជា ត្រូវបានរាប់បញ្ចូលក្នុងចំណោមប្រជាជនក្រីក្រដែលកំពុងទទួលបាននូវផលប្រយោជន៍នៃកម្មវិធីគាំពារសង្គមកាន់តែទូលំទូលាយ។ គិតពីពេលចាប់ផ្តើមអនុវត្តកម្មវិធីក្នុងត្រីមាសទី១ ឆ្នាំ២០២២ រហូតដល់ដំណាច់ខែកញ្ញា ឆ្នាំ២០២៥ អ្នកផ្ទុកមេរោគអេដស៍ចំនួន ៥៣ ៨២១នាក់ បានទទួលប័ណ្ណមូលនិធិសមធម៌សុខាភិបាល ស្មើនឹង ៧៥% នៃអ្នកផ្ទុកមេរោគអេដស៍សកម្មចំនួន ៧១ ៧១៦នាក់។

៤- ប្រជាជនគន្លឹះចំនួន ១៥ ៤៥៤នាក់ បានទទួលប័ណ្ណមូលនិធិសមធម៌សុខាភិបាល នៅត្រីមាសទី១ ឆ្នាំ២០២៥។

៥- រាជរដ្ឋាភិបាលបានដាក់ចេញនូវគោលនយោបាយជាតិបញ្ចប់អេដស៍ និងចីរភាពកម្មវិធីអេដស៍ សម្រាប់ឆ្នាំ២០២៣-២០២៨ ដើម្បីឆ្ពោះទៅបញ្ចប់អេដស៍ដែលជាបញ្ហាសុខភាពសាធារណៈ។

៦- យើងកំពុងពង្រឹងប្រព័ន្ធជាតិឆ្លើយតបនឹងមេរោគអេដស៍ និងជំងឺអេដស៍ សំដៅជំរុញចរន្តជាតិមួយដ៏មុតស្រួច ដោយបង្កលក្ខណៈឱ្យគ្រប់ក្រសួង ស្ថាប័ន រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ឃុំ សង្កាត់ ដំណើរការគណៈកម្មាធិការប្រយុទ្ធនឹងជំងឺអេដស៍គ្រប់លំដាប់ថ្នាក់ ជាមួយនឹងកិច្ចសហការយ៉ាងជិតស្និទ្ធជាមួយដៃគូអភិវឌ្ឍ អង្គការអន្តរជាតិ រួមទាំងអង្គការមិនមែនរដ្ឋាភិបាល អង្គការសង្គមស៊ីវិលជាតិ និងអន្តរជាតិ។

ជាមួយនឹងសមិទ្ធផលខាងលើ យើងទាំងអស់គ្នាត្រូវខិតខំបន្ថែមទៀត ក្នុងការផ្សព្វផ្សាយស្វែងរកអ្នកផ្ទុកមេរោគអេដស៍ចំនួនប្រមាណជាង ៤ ០០០នាក់ ដែលមិនទាន់បានដឹងពីស្ថានភាពរបស់ពួកគេឱ្យមកទទួលសេវាធ្វើតេស្តរកមេរោគអេដស៍ ដើម្បីទទួលបានការព្យាបាលទាន់ពេល និងខិតខំកាត់បន្ថយអត្រាបោះបង់ការថែទាំ និងព្យាបាលរបស់អ្នកផ្ទុកមេរោគអេដស៍។ ជាមួយគ្នានេះ គ្រប់ក្រសួង ស្ថាប័ន រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ឃុំ សង្កាត់ ត្រូវដើរតួនាទីនាំមុខជាអ្នកសម្របសម្រួលកម្មវិធីបង្ការទប់ស្កាត់ការរីករាលដាលនៃមេរោគអេដស៍ ដោយគ្មានការរើសអើងមាក់ងាយ និងផ្តោតការយកចិត្តទុកដាក់ជាពិសេសចំពោះប្រជាជនគន្លឹះដូចជា ក្រុមបុរសរួមភេទជាមួយបុរស ក្រុមបំប្លែងភេទ ក្រុមអ្នកបម្រើការនៅសេវាកម្សាន្ត អ្នកប្រើប្រាស់គ្រឿងញៀន និងក្រុមយុវវ័យ ដែលត្រូវទាក់ទាញឱ្យមកធ្វើតេស្តរកមេរោគអេដស៍ឱ្យបានឆាប់ និងទទួលបានសេវាព្យាបាលមេរោគអេដស៍ក្នុងថ្ងៃតែមួយ។

ដើម្បីឈានទៅសម្រេចជោគជ័យនៃការបង្ការទប់ស្កាត់ការរីករាលដាលនេះ ស្ថាប័នរដ្ឋទាំងអស់ ទាំងថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ត្រូវសហការឱ្យបានជិតស្និទ្ធជាមួយប្រតិបត្តិករ ព្រមទាំងជាមួយសហគមន៍នៃប្រជាជនគន្លឹះទាំងអស់ ក្នុងការផ្តល់មធ្យោបាយបង្ការ និងផ្សព្វផ្សាយសារអំពីសុវត្ថិភាពនៃការរួមភេទដូចជា ការប្រើប្រាស់ស្រោមអនាម័យ (Condom) ការប្រើឱសថបង្ការមុនពេលប្រឈម (PrEP) ការប្រើឱសថបង្ការក្រោយពេលប្រឈម (PEP) និង ការធ្វើតេស្តរកមេរោគអេដស៍ជាដើម។

ទន្ទឹមនឹងនេះ យើងត្រូវរួមគ្នាធ្វើយ៉ាងណាបញ្ចប់ការចម្លងមេរោគអេដស៍ពីម្តាយទៅកូន តាមមាគ៌ារបស់សម្តេចកិត្តិព្រឹទ្ធបណ្ឌិត **ប៊ុន រ៉ានី ហ៊ុនសែន** ប្រធានកាកបាទក្រហមកម្ពុជា និងជាឥស្សរជនឆ្នើមថ្នាក់ជាតិនៃវេទិកាភាពជាអ្នកដឹកនាំតំបន់អាស៊ី-ប៉ាស៊ីហ្វិក ឆ្លើយតបមេរោគអេដស៍ ជំងឺអេដស៍ និងការអភិវឌ្ឍនៅកម្ពុជា។

«**យកឈ្នះការរំខាន បរិវត្តកម្មឆ្លើយតបនឹងជំងឺអេដស៍**» ទាមទារឱ្យប្រទេសជាសមាជិក ជាពិសេសប្រទេសកម្ពុជាយើងធ្វើសកម្មភាពឱ្យកាន់តែមានប្រសិទ្ធភាពខ្ពស់ ឈានឆ្ពោះទៅសម្រេចគោលដៅ ៩៥-៩៥-៩៥ ដោយត្រូវលើកកម្ពស់គុណភាពនិងភាពសក្តិសិទ្ធិនៃសេវាព្យាបាល ថែទាំ ការធ្វើតេស្ត និងការបង្ការមេរោគអេដស៍ ព្រមទាំងលុបបំបាត់របាំងនៃការមាក់ងាយ រើសអើង ព្រមជាមួយការគាំទ្រនិងការចូលរួមពីគ្រប់ភាគី និងតួអង្គពាក់ព័ន្ធ។

ដើម្បីសម្រេចបាននូវការបញ្ចប់អេដស៍ ដែលជាការគំរាមកំហែងដល់សុខភាពសាធារណៈ ទូលព្រះបង្គំខ្ញុំព្រះករុណា ខ្ញុំសូមលើកឡើងនូវចំណុចមួយចំនួនដូចខាងក្រោម៖

**ទី១-** អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ ត្រូវបន្តដឹកនាំសម្របសម្រួល និងអនុវត្តគោលនយោបាយជាតិបញ្ចប់អេដស៍ និងចីរភាពកម្មវិធីអេដស៍ សម្រាប់ឆ្នាំ២០២៣-២០២៨ របស់រាជរដ្ឋាភិបាល ឱ្យសម្រេចគោលដៅដែលបានកំណត់។

**ទី២-** គណៈកម្មាធិការប្រយុទ្ធនឹងជំងឺអេដស៍ក្រសួង ស្ថាប័ន រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ និងគណៈកម្មាធិការប្រយុទ្ធនឹងជំងឺអេដស៍ឃុំ សង្កាត់ ត្រូវចូលរួមគាំទ្រនិងអនុវត្តគោលនយោបាយជាតិបញ្ចប់អេដស៍ និងចីរភាពកម្មវិធីអេដស៍ សម្រាប់ឆ្នាំ២០២៣-២០២៨ របស់រាជរដ្ឋាភិបាល ឱ្យបានសកម្មជាទីបំផុត។

**ទី៣-** ក្រសួងសុខាភិបាលពង្រីក ពង្រឹងកម្មវិធីបង្ការ ថែទាំ និងព្យាបាលដោយប្រើវិធីសាស្ត្រថ្មីៗ ដែលមានប្រសិទ្ធភាព ដើម្បីសម្រេចបាននូវគោលដៅនៃការឆ្លងថ្មីនៃមេរោគអេដស៍ក្នុងរង្វង់ជាង ២០០ករណី ក្នុងមួយឆ្នាំ និងកាត់បន្ថយការស្លាប់ដោយមេរោគអេដស៍តិចជាង ២០០ករណី ក្នុងមួយឆ្នាំ។

**ទី៤-** គ្រប់ក្រសួង ស្ថាប័ន រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ឃុំ សង្កាត់ ធ្វើការរួមគ្នាជាពហុវិស័យ សហការជិតស្និទ្ធជាមួយកាកបាទក្រហមកម្ពុជា អង្គការមិនមែនរដ្ឋាភិបាល អង្គការសង្គមស៊ីវិល វិស័យឯកជន និងសហគមន៍ ដើម្បីលុបបំបាត់ការមាក់ងាយនិងការរើសអើងអ្នកផ្ទុកមេរោគអេដស៍ និងក្រុមប្រជាជនគន្លឹះ។

**ទី៥-** ក្រសួងសុខាភិបាល ក្រសួងផែនការ ក្រុមប្រឹក្សាជាតិគាំពារសង្គម និងបេឡាជាតិសន្តិសុខសង្គម បន្តកិច្ចសហការពង្រីក និងពង្រឹងការផ្តល់ប័ណ្ណមូលនិធិសមធម៌សុខាភិបាល ដល់អ្នកផ្ទុកមេរោគអេដស៍ និងប្រជាជនគន្លឹះឱ្យបានតាមគោលដៅកំណត់។

**ទី៦-** អង្គការដៃគូអន្តរជាតិ សូមជួយគាំទ្រការពង្រឹងប្រព័ន្ធជាតិ តាមរយៈការបន្តផ្តល់ជំនួយហិរញ្ញវត្ថុ និងបច្ចេកទេសក្នុងការឆ្លើយតបមេរោគអេដស៍និងជំងឺអេដស៍ក្នុងប្រទេស ក្រោមការដឹកនាំសម្របសម្រួលរបស់អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍។

ជាថ្មីម្តងទៀត ទូលព្រះបង្គំ ខ្ញុំព្រះករុណា ខ្ញុំសូមថ្លែងអំណរព្រះគុណចំពោះព្រះថេរានុត្ថេរៈគ្រប់ព្រះអង្គ សូមអរគុណចំពោះបងប្អូនជនរួមជាតិ ថ្នាក់ដឹកនាំ មន្ត្រីរាជការ កងកម្លាំងប្រដាប់អាវុធគ្រប់ប្រភេទ កាកបាទក្រហមកម្ពុជា អង្គការដៃគូជាតិ អន្តរជាតិ អង្គការមិនមែនរដ្ឋាភិបាល វិស័យឯកជន សប្បុរសជននានា អ្នកផ្ទុកមេរោគអេដស៍ និងប្រជាជនគន្លឹះ ដែលបានយកចិត្តទុកដាក់ប្រឹងប្រែងនិងរួមចំណែកក្នុងការឆ្លើយតបមេរោគអេដស៍ និងជំងឺអេដស៍នៅកម្ពុជា ឱ្យទទួលបានជោគជ័យគួរជាទីមោទនៈនាពេលកន្លងមករហូតដល់ពេលនេះ និងសូមចូលរួមសហការល្អបន្តទៀត ដើម្បីបញ្ចប់ជំងឺអេដស៍ដែលជាបញ្ហាសុខភាពសាធារណៈនៅកម្ពុជា នាពេលខាងមុខ។

ជាទីបញ្ចប់ ទូលព្រះបង្គំ ខ្ញុំព្រះករុណា ខ្ញុំសូមថ្វាយព្រះពរសម្តេចព្រះមហាសង្ឃរាជទាំងពីរគណៈ និងថ្វាយប្រគេនពរសម្តេចព្រះថេរានុត្ថេរៈគ្រប់ព្រះអង្គ និងសូមប្រសិទ្ធពរជូនចំពោះសម្តេច ទ្រង់ ឯកឧត្តម លោកជំទាវ លោកអ្នកឧកញ៉ា អ្នកឧកញ៉ា ឧកញ៉ា លោក លោកស្រី ក្មួយៗយុវជន យុវតី និស្សិត សិស្សានុសិស្ស និងបងប្អូនជនរួមជាតិទាំងអស់ សូមបានប្រកបដោយពុទ្ធពរទាំង៤ប្រការគឺ **អាយុ វណ្ណៈ សុខៈ ពលៈ** កុំបីឃ្លៀងឃ្លាតឡើយ។

ថ្ងៃពុធ ៦កើត ខែមិគសិរ ឆ្នាំម្សាញ់ សប្តស័ក ព.ស.២៥៦៩

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី២៦ ខែវិច្ឆិកា ឆ្នាំ២០២៥

**នាយករដ្ឋមន្ត្រី**

**សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត**